ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

# សាលាបឋមសិក្សា សោថ់ហ្វក (Southwark)

*"ទោះជាភាសាអ្វីក៏ដោយ ការញញឹមគឺដូចគ្នាទាំងអស់"*

**Mr. Andrew Lukov**, *នាយកសាលា*

1835 South 9th Street Philadelphia, PA 19148
ទូរស័ព្ទ៖ ២១៥-៩៥២-៨៦០៦ ទូរសារ៖ ២១៥-៩៥២-៨៦៧០

## ច្បាប់អំពី ការសម្លុតធ្វើបាបគេ និងការយាយី នៅសាលាបឋមសិក្សា សោថ់ហ្វក

**តើអ្វីទៅដែលជា ការសម្លុតធ្វើបាបគេ?**

ការសម្លុតធ្វើបាបគេ គឺនៅពេលដែលអ្នកណាម្នាក់និយាយច្រំដែលៗ ក្នុងគោលបំណង និយាយ ឬធ្វើអ្វីៗដែលអាក្រក់ ឬមានគ្រោះថ្នាក់ ដល់អ្នកដទៃ ដែលមិនអាចការពារខ្លួនបាន។ មានចំណុចបីសំខាន់ៗ នៃការសម្លុតធ្វើបាបគេ៖

១. មានអាកប្បកិរិយាច្រឡើសបើស
២. អាកប្បកិរិយាដែលធ្វើឡើងច្រំដែលៗ អស់រយៈពេលយូរ
៣. អំណាច ឬកម្លាំង ដែលមិនស្មើគ្នា

ការសម្លុតធ្វើបាបគេ អាចជាអំពើធ្វើដោយផ្ទាល់៖ ការវាយតប់ ពាក្យឡកឡឺយ និងហៅឈ្មោះបង្អាប់។ ការសម្លុតធ្វើបាបគេ អាចជាអំពើមិនធ្វើដោយផ្ទាល់៖ ពាក្យចចាមអារ៉ាម ការបដិសេធមិនឲ្យចូលរួមសកម្មភាព និង ការសម្លុតធ្វើបាបគេតាមគ្រឿងអេឡិចត្រូនិច។

**តើអ្វីទៅដែលជា ការយាយី?**

ការយាយីគឺជា ពាក្យសំដី ការសរសេរ រូបគំនូរ ដែលគេមិនស្វាគមន៍ និង/ឬ ការធ្វើទៅលើរាងកាយដែលទាក់ទងដល់ ភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ទំនោរនៃសេចក្តីស្រឡាញ់ (ដឹង ឬតាមការយល់ឃើញ) ដើមកំណើត សាសនា ពិការភាព ចំណេះដឹងភាសាអង់គ្លេស ស្ថានភាពសេដ្ឋកិច្ច និង/ឬ ជំនឿនយោបាយ។

**គេមិនទទួលស្គាល់អាកប្បកិរិយាទាំងពីរខាងលើនេះទេ។ គេសុំឲ្យសិស្សានុសិស្សរាយការណ៍នូវឧប្បត្តិហេតុនៃ ការសម្លុតធ្វើបាប និង/ឬ ការយាយី ទាំងអស់ទៅសមាជិកនៃបុគ្គលិកសាលាណាម្នាក់។ សុំឲ្យមាតាបិតាទាក់ទងមកអ្នកផ្តល់ឱវាទរបស់យើង ដើម្បីរាយការណ៍នូវឧប្បត្តិហេតុនៃ ការសម្លុតធ្វើបាប និង/ឬ ការយាយី។**

សាលាបឋមសិល្សា សោថ់ហ្វក នឹងធ្វើការស៊ើបអង្កេតគ្រប់សេចក្តីរាយការណ៍ទាំងអស់ អំពី ការសម្លុតធ្វើបាប និង ការយាយី ហើយនឹងធ្វើសកម្មភាពដោយសមរម្យ ក្រោយពីមានការស៊ើបអង្កេតរួច។

ជនរងគ្រោះ៖ គេនឹងផ្តល់ដំណឹងដល់មាតាបិតារបស់ជនរងគ្រោះអំពីដំណាក់កាលច្បាស់លាស់ដែលសាលាបានធ្វើ ដើម្បីធ្វើអន្តរាគមន៍លើអាកប្បកិរិយា ដែលបានរាយការណ៍ តាមដានមើលអ្វីៗទៅថ្ងៃក្រោយ ហើយការពារជនរងគ្រោះពី ការផ្ចាញ់តប ឬការសងសឹក។

ជនប្រព្រឹត្តបទល្មើស៖ គេនឹងផ្តល់ដំណឹងដល់មាតាបិតារបស់ជនប្រព្រឹត្តបទល្មើសអំពីដំណាក់កាលច្បាស់លាស់ដែលសាលាបានធ្វើ ដើម្បីធ្វើអន្តរាគមន៍លើអាកប្បកិរិយាដែលបានរាយការណ៍ តាមដានមើលអ្វីៗទៅថ្ងៃក្រោយ ព្រមទាំងសំណើនៃការដាក់វិន័យ ដូចបានចែងនៅក្នុងក្រមសីលធម៌។ ការដាក់វិន័យរួមមាន តែគ្មានកំណត់ ចំពោះ៖

- ប្រជុំជាមួយមាតាបិតា
- សំបុត្របញ្ឈប់សិស្ស ដែលមាតាបិតាត្រូវមកជួបប្រជុំជាបន្ទាន់
- ការដាក់ទណ្ឌកម្មនៅពេលញ៉ាំអាហារថ្ងៃត្រង់
- ការដាក់ទណ្ឌកម្មនៅក្នុងសាលា
- ថ្នាក់សម្រាប់ការធ្វើអន្តរាគមន៍លើអាកប្បកិរិយា
- ការបញ្ជូនទៅ RtII សម្រាប់អាកប្បកិរិយា
- ការដាក់ទណ្ឌកម្មមិនឲ្យមកសាសាលា ពីមួយថ្ងៃ ទៅដប់ថ្ងៃ
- ការបញ្ជូនទៅ ការិយាល័យសវនាការនិងបណ្តេញសិស្សចេញ ដោយមានសំណូមពរពីរដ្ឋបាល ឲ្យមានការធ្វើអន្តរាគមន៍ ផ្នែកអាកប្បកិរិយា ឬការផ្លាស់ទៅសាលាផ្សេងទៀត
- ការបញ្ជូនទៅ ការិយាល័យសវនាការនិងបណ្តេញសិស្សចេញ ដោយមានសំណូមពរពីរដ្ឋបាល ឲផ្លាស់ទៅសាលាដែលមានវិន័យតឹងរឹង (សម្រាប់ថ្នាក់ទី៦-៨)

**ច្បាប់ប្រឆាំងនិងការសម្លុតធ្វើបាបរបស់សាលា សោថហ្វក**